ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚ ❖ ៚

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៣៤៥ អយក.ប្រក

# ប្រកាស

## ស្តីពី ការផ្តាច់សាលាឧបសម្ព័ន្ធ សំរោង មកជាសាលាបឋមសិក្សាពេញលក្ខណៈ

---

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត -១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.ប.ក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជា នាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតលេខ ៦៩២ អយក ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០០២ របស់ មន្ទីរ អប់រំយុវជន និង កីឡា ខេត្ត កំពង់ស្ពឺ

-តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋមសិក្សា

### សំរេច

**ប្រការ១:** ផ្តាច់សាលាឧបសម្ព័ន្ធ **សំរោង** ពីសាលាបឋមសិក្សា **ឆ្អិន** ដែលមានទីតាំងស្ថិតនៅ ភូមិ **សំរោង** ឃុំ **ត្រពាំងជោរ** ស្រុក **ឱរ៉ាល់** ខេត្ត **កំពង់ស្ពឺ** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២:** សាលាបឋមសិក្សា **សំរោង** ត្រូវដឹកនាំដោយ នាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងស្របតាមបទដ្ឋានប្រើប្រាស់ ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ៣:** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤:** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កំពង់ស្ពឺ** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **ឱរ៉ាល់** នាយកសាលាបឋមសិក្សា **សំរោង** នាយកសាលាបឋមសិក្សា **ឆ្អិន** មានភារកិច្ចអនុវត្តប្រកាសនេះ ។

**កន្លែងទទួល**

ទីស្តីការគណៈរដ្ឋមន្ត្រី

- ទីស្តីការគណៈរដ្ឋមន្ត្រី (sic) ដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាខេត្ត កំពង់ស្ពឺ

**ដើម្បីជូនជ្រាបជាពត៌មាន**

- ដូចប្រការ ៥
- កាលប្បវត្តិ-ឯកសារ ទា បស

ភ្នំពេញ , ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៣

ឧ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

អ៊ឹម ស៊ិទ្ធី